| ៥៥-វរសេនីយ៍ឯក | ឡៃ | ចន្ថា | អត្តលេខ ០៣០៧៤០ |

| | | | |
|---|---|---|---|
| ៥៦-វរសេនីយ៍ឯក | ធី | សុខា | អត្តលេខ ០១២៦៤៣ |
| ៥៧-វរសេនីយ៍ឯក | ព្រហ្ម | ពិសិដ្ឋ | អត្តលេខ ០២២៤២៥ |
| ៥៨-វរសេនីយ៍ឯក | មុំ | សារ៉ែន | អត្តលេខ ០១០៣៦៣ |
| ៥៩-វរសេនីយ៍ឯក | អ៊ុក | រ៉ាស៊ីន | អត្តលេខ ០០៣១៧៧ |
| ៦០-វរសេនីយ៍ឯក | សោម | ណារ៉ាន | អត្តលេខ ០១៤៧៤៤ |
| ៦១-វរសេនីយ៍ឯក | តឹក | សាវី | អត្តលេខ ០១៦៦៥៣ |
| ៦២-វរសេនីយ៍ឯក | លឹម | ម៉ា | អត្តលេខ ០០២០៦៩ |
| ៦៣-វរសេនីយ៍ឯក | ទ្រី | គង់ | អត្តលេខ ០០២០៦៧ |
| ៦៤-វរសេនីយ៍ឯក | អ៊ុង | ចាន់សុភ័ណ្ឌ | អត្តលេខ ០០៣៩៦០ |
| ៦៥-វរសេនីយ៍ឯក | ណាល់ | ម៉ិច | អត្តលេខ ០០៣៣៩៧ |
| ៦៦-វរសេនីយ៍ឯក | នាង | សុវណ្ណា | អត្តលេខ ០០៨៧២៥ |
| ៦៧-វរសេនីយ៍ឯក | សៅ | សារ៉ែម | អត្តលេខ ០១៤៩៩០ |
| ៦៨-វរសេនីយ៍ឯក | លី | សាលី | អត្តលេខ ០០២៧៣២ |
| ៦៩-វរសេនីយ៍ឯក | ធីវ | វុទ្ធី | អត្តលេខ ០៥៦៥១៩ |
| ៧០-វរសេនីយ៍ឯក | សុខ | វណ្ណារ៉ា | អត្តលេខ ០១០៦៦៥ |

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកត.០៦១៦.៦៥៤

លេខ: ៦៤៦ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ង្វៀន សានមានញ៉ិន** (NGUYEN SAN MIEN NHAN) ជនជាតិវៀតណាម សញ្ជាតិវៀតណាម កើតថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧១ នៅខេត្តកឹងប៉ាយ សាធារណរដ្ឋសង្គមនិយមវៀតណាម ដោយប្តូរឈ្មោះជា **ធា ខា** (TEA KHA)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១៦០៦. ៦៥៥

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦

លេខៈ ៦៥០ ស.ណ
**សំណៅចេញមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៦/៦៤៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឆេង ឈីហេង** (CHENG CHI HENG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៧ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្ដូរឈ្មោះជា **លី វាសនា** (LY VEASNA)។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៦០៦ . ៦៥៦

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦ ៤ ៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **សាត់ឌឺឡែន ប៊ែរី** (SUTHERLAND BARRY) ជនជាតិកាណាដា សញ្ជាតិកាណាដា កើតថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៦២ នៅទីក្រុងវ៉ូដស្តុក ប្រទេសកាណាដា។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៦០៦.៦៥៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦៥៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៣២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ឆាន រួយ អេហ្គ្រីខលឆឺរល គ្រេឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**សម្រេច**

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ធាន រួយ អេហ្គ្រីខលឆឺរ៉ល ត្រេឌ** (TIAN RUI AGRICULTURAL TRADE SEZ) ដែលមានទីតាំងស្ថិតនៅ ភូមិជួនរៀត ភូមិអូរតាពូង ភូមិព្រីងទឹក និងភូមិស្រែឆ្លក ឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ធាន រួយ អេហ្គ្រីខលឆឺរ៉ល ត្រេឌ** មានទំហំ ១.០១៣.៦០០ ម៉ែត្រក្រឡា (មួយលានដប់បីពាន់ប្រាំមួយរយម៉ែត្រក្រឡា) ដូចមានប្លង់ទីតាំង ព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ធាន រួយ អេហ្គ្រីខលឆឺរ៉ល ត្រេឌ** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ធាន រួយ អេហ្គ្រីខលឆឺរ៉ល ត្រេឌ** នេះ នឹងស្ថិតក្រោមវិសាលភាព នៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងក្រុមហ៊ុន ផាន រូយ (ខេមបូឌា) អេហ្គ្រីខលឆឺរល ខូអបផីរេសិន អេសអ៊ីហ្សិត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងខ្លួន២ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្ដាសោភា**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ**សម្ដេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


ប្លង់បង្ហាញទីតាំងដីស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសរបស់ក្រុមហ៊ុន ធានរួយ (ខេមបូឌា) អេហ្គ្រីខលឆឺរ៉លខូអបឌីវេសិន អេសអ៊ីហ្សិត
(ស្ថិតនៅភូមិដូនអៀត ភូមិអូរតាពូង ភូមិព្រីងទឹក និងភូមិស្រែធ្លក ឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ)
464000
464500
465000
465500
1261500
1261000
1260500
1260000
1259500
មាត្រដ្ឋាន 1:7,800
ផ្លូវលេខ ១៣០
BM_01
តារាងនិយាមកានៃបង្គោលប្រថពីវិភាគ
ប្រភព: អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
Projection UTM, Zone 48N, Datum WGS 84.
Point_ID | Northing (m) | Easting (m)
BM_01 | 1260621.186 | 464916.750
សញ្ញាសំគាល់
ក្រឡាផ្ទៃដី: ១០១.៣៦ ហិកតា
DGPS (Lieca UNO)
វាស់វែង និងគូរដោយ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើត ការគ្រប់គ្រង និងការចាត់ចែងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ និងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការបង្កើត ការគ្រប់គ្រង និងការចាត់ចែងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិនិងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ដែលសរសេរជាអក្សរកាត់ថា **ម.ស.ជ.**។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិឲ្យមានប្រសិទ្ធភាព ដើម្បីជួយទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្ដប់លើការគ្រប់គ្រងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ប្រភពធនធាននិងការគ្រប់គ្រងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ

**មាត្រា៤ .-**

មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានប្រភពធនធានមកពី៖

- វិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល
- វិភាគទានរបស់ស្ថាប័នជាតិផ្សេងៗទៀត
- ចំណែកនៃប្រាក់ង្វាន់ពីកម្រៃសេវាសាធារណៈពីវិស័យវប្បធម៌និងវិចិត្រសិល្បៈ
- ជំនួយរបស់អង្គការជាតិនិងអន្តរជាតិនានា
- អំណោយពីសប្បុរសជន វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល
- ប្រភពធនធានផ្សេងៗទៀត។

រាល់ធនធានខាងលើ ត្រូវបញ្ចូលក្នុងគណនីមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ។

**មាត្រា៥ .-**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវបង្កើតគណនីមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិដោយឡែកសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- អភិរក្សនិងអភិវឌ្ឍសិល្បៈជាតិ ពិសេសទម្រង់សិល្បៈដែលកំពុងប្រឈមនិងត្រូវសង្គ្រោះបន្ទាន់
- សិក្សាស្រាវជ្រាវនិងបង្កើតស្នាដៃ
- ផ្សព្វផ្សាយនិងលើកតម្លៃសិល្បៈជាតិ
- បណ្ដុះបណ្ដាលធនធានមនុស្សសម្រាប់វិស័យសិល្បៈ
- ការងារផ្សេងៗទៀតដែលពាក់ព័ន្ធ។

**មាត្រា៦ .-**

នីតិវិធីនៃការប្រើប្រាស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ

**មាត្រា៧ .-**

មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ។

សមាសភាពគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ រួមមាន៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| - តំណាងក្រសួងព័ត៌មាន | ១រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ | | លេខាធិការអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៨ .-**

គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- កំណត់គោលនយោបាយ យុទ្ធសាស្ត្រគ្រប់គ្រងនិងចាត់ចែងប្រើប្រាស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ
- ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន បណ្តាដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជនក្នុងការកៀរគរធនធានសម្រាប់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ
- ពិនិត្យនិងសម្រេចលើគម្រោងចំណូលចំណាយរបស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ សម្រាប់បម្រើឲ្យការទ្រទ្រង់និងការអភិវឌ្ឍសិល្បៈជាតិ តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន
- តាមដានការអនុវត្តនិងពិនិត្យលើរបាយការណ៍អំពីស្ថានភាពការងារ និងដំណើរការរបស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីដំណើរការមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ និង
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូននិងតាមការចាំបាច់ ដែលបម្រើឲ្យមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ។

**មាត្រា៩ .-**

គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅទីស្តីការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងដឹកនាំដោយលេខាធិការអចិន្ត្រៃយ៍។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ។

**មាត្រា១០ .-**

គណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ មានត្រាដោយឡែកសម្រាប់ដំណើរការការងារ

**ជំពូកទី៤**
**អវសានប្បញ្ញត្តិ**

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៧០០.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** -.បំពាក់មេដាយជូនមន្ត្រីរាជការ និងសប្បុរសជន ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងបានចូលរួមកសាងអភិវឌ្ឍន៍ភូមិ ឃុំ ស្រុក ក្រុង ក្នុងខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោមៈ

**ក-មេដាយស្ថាបនាជាតិ ថ្នាក់ មាសៈ**

| | | | |
|---|---|---|---|
| ១- លោក | **ប៊ុន** | **វិសិដ្ឋ** | សប្បុរសជន |
| ២- លោក | **ហ៊ូ** | **វណ្ណី** | សប្បុរសជន |

**ខ-មេដាយការងារ ថ្នាក់ ប្រាក់ៈ**

| | | | |
|---|---|---|---|
| ១- លោក | **ហែម** | **សោភ័ណ** | បុគ្គលិកមណ្ឌលសុខភាពព្រៃនប់ |
| ២- កញ្ញា | **ឃីម** | **ញ៉ាន** | បុគ្គលិកមណ្ឌលសុខភាពព្រៃនប់ |
| ៣- កញ្ញា | **ឆាវ** | **សុនីតា** | បុគ្គលិកមណ្ឌលសុខភាពព្រៃនប់ |

៤- កញ្ញា **ថន មុន្នីរៈ** បុគ្គលិកមណ្ឌលសុខភាពព្រៃនប់

៥- លោកស្រី **ទ្រៀង គីមឡាយ** បុគ្គលិកមណ្ឌលសុខភាពព្រៃនប់

៦- លោកស្រី **ថុន ស្រីល័ក្ខ** បុគ្គលិកមណ្ឌលសុខភាពព្រៃនប់

**មាត្រា ២-.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ..៧៧០១..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងមុខតំណែងនាយនគរបាលជាន់ខ្ពស់ ចំនួន ០២រូប ជាអនុប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន ដូចខាងក្រោម ៖

១-លោកវរសេនីយ៍ឯក **ឈឹម ថន** អត្តលេខ ០៩១៦

២-លោកវរសេនីយ៍ឯក **ហាច ចាន់សិទ្ធី** អត្តលេខ ០៦៦៧៨ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ  នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤  ខែ កញ្ញា  ឆ្នាំ ២០១៣  ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា  ឆ្នាំ ១៩៩៤  ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦  ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨  ខែកក្កដា ឆ្នាំ ២០០១  ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ  ៦៥អនក្រ.បក ចុះថ្ងៃទី ១៤  ខែ កញ្ញា  ឆ្នាំ ២០០០  ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ៈ** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-ឧត្តមសេនីយ៍ទោ **អ៊ុំ  មុន្នី**  អត្តលេខ ០០៨៥៦៩ ជា អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា

២-ឧត្តមសេនីយ៍ទោ **កែវ  សារុណា**  អត្តលេខ ០០១៦៩០ ជា អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា

៣-ឧត្តមសេនីយ៍ទោ **កើត  ម៉ូលីន**  អត្តលេខ ០០១៤៦៤ ជា អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៤-ឧត្តមសេនីយ៍ទោ **ឈួន យូ**  អត្តលេខ ០៣៧១៨៧ ជា អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៥-ឧត្តមនាវីទោ **ហ៊ីង  ពុធដារ៉ា** អត្តលេខ ០០១១១៣ ជា មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងទឹក

៦-ឧត្តមនាវីទោ **សេង ណារិន**  អត្តលេខ ០១០២៨៣ ជា មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងទឹក

៧-ឧត្តមនាវីទោ **ឆា តឹមតុល** អត្តលេខ ០២២៩២០ ជា មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងទឹក

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧០៣.អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ខិន ខិនដា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តកែប។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២០៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោកស្រី **ទិត សុខា** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៣ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលក្រុងកែប ខេត្តកែប។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិដល់មន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ដំឡើងឋានន្តរស័ក្តជាករណីពិសេសដល់មន្ត្រីរាជការ ចំនួន ០៨ នាក់ ពីឋានន្តរស័ក្តអនុមន្ត្រី ទៅក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៖

១. លោកជំទាវ **ហាន សុគន្ធា** ពីអនុមន្ត្រី ថ្នាក់លេខ ៤ មកវរមន្ត្រី ថ្នាក់លេខ ៤

២. លោក **ទ៉ាំង សេរីរតនៈ** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ៤

៣. លោក **ឈុន ម៉ិនណារ៉ា** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ៤

៤. លោក **ឌី ពៀច** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ៤
៥. លោក **ឯក សំឡូ** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ៤
៦. លោក **សុខ សាវុធ** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ៤
៧. លោក **ស៊ឿ ចាន់ធី** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ៤
៨. លោក **ឈឹម សាមុន** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ៤។

**មាត្រា ២.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្ដីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ពិន ច្រាកដ** ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្រសួងសុខាភិបាល ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប។

**មាត្រា ២ :** ក្នុងរយៈពេលនៃការមកបំពេញភារកិច្ចថ្មីនេះលោក **ពិន ច្រាកដ** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **អ៊ុក សំអុល** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១ ពីអភិបាល នៃគណៈអភិបាលក្រុងបានលុង ឲ្យទៅបម្រើការងារនៅសាលាខេត្តរតនគិរី។

**មាត្រា ២ :** តែងតាំងលោក **ខិន ណែល** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលក្រុងបានលុង ខេត្តរតនគិរី។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤០៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១:** តែងតាំងលោក **ហម សារាវុធ** ជាអនុប្រធានរដ្ឋបាលព្រៃឈើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៧០ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ០៥គ្រឿង ជូននាយទាហាន និងសប្បុរសជន ចំនួន ០៥រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយអភិវឌ្ឍន៍អង្គភាពយោធភូមិភាគទី៣ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

១- ឧត្តមសេនីយ៍ត្រី **លឹម សុផន** អត្តលេខ ០០០៩២៤ នាយរងសេនាធិការ យោធភូមិភាគទី៣

២- វរសេនីយ៍ឯក **ហួរ ហេង** អត្តលេខ ១៨៦៤៨២ នាយរងសេនាធិការ យោធភូមិភាគទី៣

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១- វរសេនីយ៍ឯក **គង់ គឿន** អត្តលេខ ១៥៧៨៣៩ នាយការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគទី៣

២- វរសេនីយ៍ទោ **ជា ម៉ុល** អត្តលេខ ០១០៤៤០ នាយរងការិយាល័យទី២ យោធភូមិភាគទី៣

៣- អនុសេនីយ៍ឯក **ឆេង ឡុង** អត្តលេខ ១៩៧២៨៦ មេបញ្ជាការរង កងរាជអាវុធហត្ថស្រុកឱរ៉ាល់

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧០.អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ចំនួន ១១គ្រឿង ជូននាយទាហាន និងសប្បុរសជន ចំនួន ១១រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយអភិវឌ្ឍន៍អង្គភាពយោធភូមិភាគទី៣ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

១- វរសេនីយ៍ទោ **មាស ទ្រី** អត្តលេខ ០១៥៦៩៤ នាយការិយាល័យទី១ យោធភូមិភាគទី៣

២- វរសេនីយ៍ត្រី **តាំង ម៉េងហួត** អត្តលេខ ០៧៦៩០៥ នាយផ្នែកវិស្វកម្ម តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

៣- លោក **ចេង ឃីម** សប្បុរសជននៅរាជធានីភ្នំពេញ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១- អនុសេនីយ៍ឯក **ប៉ែន ស៊ីទុត្ថា** អត្តលេខ ៦៧១៨៤ នាយផ្នែក នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកទេស

២- អនុសេនីយ៍ឯក **ហង្ស សុភាព** អត្តលេខ ៦៥២៨៥ នាយរងផ្នែក នាយកដ្ឋានភស្តុភារនិងសម្ភារបច្ចេកទេស

៣- អនុសេនីយ៍ត្រី **ម៉ៅ សុធាវី** អត្តលេខ ៦៣១១១ នាយរងផ្នែក នាយកដ្ឋានចារកម្ម

៤- អនុសេនីយ៍ត្រី **ម៉ាង ឈុនណា** អត្តលេខ ៥៨២៩៨ នាយរងផ្នែក ស្នងការនគរបាលខេត្តកណ្តាល

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

១- វរសេនីយ៍ត្រី **ឃុន ចំនូត្រីស្នា** អត្តលេខ ២៥៩៦៦ នាយផ្នែកគ្រប់គ្រងគោលដៅអាជីវកម្មរូបិយវត្ថុ

២- អនុសេនីយ៍ឯក **ប៉ែន រចនា** អត្តលេខ ០៤១៤១២ នាយរងការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករងកែប

៣- អនុសេនីយ៍ឯក **សាំង យ៉ាទ** អត្តលេខ ០៨៤៥៦៣ មេបញ្ជាការរង វរសេនាតូច ការពារព្រំដែន លេខ៣០១ តំបន់ប្រតិបត្តិការសឹករងតាកែវ

៤- អនុសេនីយ៍ត្រី **ឡុញ សុឃឿន** អត្តលេខ ១៣៧៨០៧ ជំនួយការផ្នែកវិស្វកម្ម យោធភូមិភាគទី៣

**មាត្រា ២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៧១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយសុវត្ថារា
# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**សម្រេច**

**មាត្រា១.** បំពាក់មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន៤៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

| | |
|---|---|
| ១-លោកស្រី ហូ ដានី | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង |
| ២-លោក រៀង សុម៉ាន់ | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង |
| ៣-លោក រស់ វិសិទ្ធ | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង |

**ខ-មេដាយសុវត្ថារា ថ្នាក់ សេនា**

| | |
|---|---|
| ១-លោក តូច ឈួនសៅរ័ទ្ធ | ប្រធានអង្គភាពរដ្ឋាករទឹកខេត្តបាត់ដំបង |
| ២-លោក កើង សុខខេង | ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង |
| ៣-លោក ទុយ ប៊ុនសេរីទ្ធ | អនុប្រធានសាខា នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤-លោក មៀច ផុនសុភា | ប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |

**គ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ**

| | |
|---|---|
| ១-លោក អ៊ិត ភ្លឹង | អនុប្រធានអង្គភាពរដ្ឋាករទឹកខេត្តបាត់ដំបង |
| ២-លោកស្រី សេង សុវត្ថិ | អនុប្រធានអង្គភាពរដ្ឋាករទឹកខេត្តបាត់ដំបង |
| ៣-លោក ទឹម ផាន់ណា | ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង |

| | |
|---|---|
| ៤-លោក គង់ សុភ័ក្ត្រ | ប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង |
| ៥-លោក ឈឿម សុភា | អនុប្រធានការិយាល័យ នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង |
| ៦-លោក ឃន ណារិទ្ធ | ប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៧-លោក នូ ស៊ាន | ប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៨-លោក សេង សៀន | ប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៩-លោក ទុយ ណង | ប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១០-លោក សំបូរ ថាវីរៈ | ប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១១-លោក ចាន់ សារិត | ជំនួយការ នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១២-លោកស្រី លឿង សុខា | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១៣-លោក គីម ឡូ | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១៤-លោកស្រីភូ ពេជាជា | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១៥-លោកស្រី ប៊ុន ប៊ិត | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១៦-លោក ផន វី | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១៧-លោកស្រី សំបូរ ចាន់ណា | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១៨-លោក ជៀប វណ្ណនី | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ១៩-លោក ជុំ រ័ត្ន | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២០-លោក វ៉ុង សាឌីន | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២១-លោក អ៊ុក សំអ៊ុន | អនុប្រធានផ្នែក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២២-លោក សៀម រិន | ជំនួយការ នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២៣-លោក ឃិន មន្ថា | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២៤-លោក ខេង ប៊ុនយៀង | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២៥-លោក មូល សុវត្ថិ | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២៦-លោក គុណ គីមហាន់ | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២៧-លោក ភ្លឹង វង់ជ្រីឌី | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២៨-លោក ឈឹម បុរី | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ២៩-លោក ពិន សុផល | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៣០-លោក សឿម ភិរុន | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៣១-លោក ហួន ចន្ថា | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៣២-លោក វ៉ាត វីរៈ | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៣៣-លោក ម៉ោង សំបូរ | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៣៤-លោក វ៉ុង ណារិន | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |
| ៣៥-លោក ហង់ លឿត | បុគ្គលិក នៃអង្គភាពផ្គត់ផ្គង់ទឹកខេត្តបាត់ដំបង |

| | |
|---|---|
| ៣៦-លោក ទុយ ណន | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តបាត់ដំបង |
| ៣៧-លោក ហ៊ឹម ស៊ីផាន់ | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តបាត់ដំបង |
| ៣៨-លោក ហ៊ិន ហុងយត | បុគ្គលិក នៃអង្គភាពរដ្ឋាករទឹកខេត្តបាត់ដំបង |
### ប្រការ ៥.- ការលើកលែងអាករលើតម្លៃបន្ថែម

ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់មិនជាប់អាករ។

**ប្រការ ៦.-** **ឥណទានអាករលើធាតុចូល**

ឥណទានអាករលើធាតុចូលលើការនាំចូល ឬការទិញក្នុងស្រុក នូវសម្ភារៈនិងវត្ថុធាតុដើមសម្រាប់ធ្វើកសិកម្មដាំដុះផលិតផលកសិកម្មមិនទាន់កែច្នៃ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃមាត្រា ២៩ ដល់មាត្រា ៤១ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ ៧.-** **ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ២៨៨៦........សហវ

# ប្រកាស
# ស្តីពី
# ការចុះបញ្ជីពន្ធដារ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១៨១៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការចុះបញ្ជីពន្ធដារ ស្របតាមមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះមានគោលដៅដូចខាងក្រោម÷

- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រង ឱ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យរបស់អ្នកជាប់ពន្ធ
- គាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យបានកាន់តែល្អប្រសើរ
- គាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

- ពាក្យ "**ការចុះបញ្ជីពន្ធដារ**" សំដៅដល់ការចុះបញ្ជី អ្នកជាប់ពន្ធទាំងឡាយដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ពាក្យ "**អ្នកជាប់ពន្ធ**" សំដៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។
- ពាក្យ "**សកម្មភាពសេដ្ឋកិច្ច**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើ ជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។
- ពាក្យ "**អាជីវកម្ម**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលពីការផលិតនិងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួលឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត។

**ប្រការ ៥.- កាតព្វកិច្ចចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយ ត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

**ប្រការ ៦.- ការស្នើសុំចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដោយត្រូវបំពេញ

ទម្រង់ចុះបញ្ជីដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងតម្រូវឱ្យភ្ជាប់មកជាមួយនូវឯកសារដូចមានកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ ៧.- ឯកសារ និងការតម្រូវ សម្រាប់ការចុះបញ្ជីពន្ធដារ**

**១- អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ**

**ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ**

ប្រធាន ឬអ្នកតំណាងរបស់ ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ឬ/និង
  - លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)
- **ឯកសារបញ្ជាក់អត្តសញ្ញាណ ប្រធានឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥ x ៤៥មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះនិងចុះហត្ថលេខាម្ចាស់រូបថត នៅខាងខ្នង
- **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**ខ. សហគ្រាសឯកបុគ្គល និងសហគ្រាសនីតិបុគ្គល**

ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ត្រូវបានតម្រូវឱ្យមកថតរូប ស្កែនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ករណីប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាសដែលមានសញ្ជាតិបរទេស ហើយស្នាក់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមិនអាចអញ្ជើញមកថតរូប ស្កែនម្រាមដៃ ត្រូវធ្វើលិខិតផ្ទេរសិទ្ធិឱ្យអ្នកតំណាងណាមួយនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ មកថតរូបនិងស្កែនម្រាមដៃជំនួសបាន និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវប័ណ្ណពន្ធប៉ាតង់ ឬ/និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ចំពោះប្រធានក្រុមប្រឹក្សាភិបាលឬម្ចាស់សហគ្រាសមានសញ្ជាតិបរទេស តែស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រធានក្រុមប្រឹក្សាភិបាលឬម្ចាស់សហគ្រាសមានសញ្ជាតិខ្មែរ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កែនម្រាមដៃ និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវ

ប័ណ្ណពន្ធប៉ាតង់ ឬ/និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប និងស្កែនម្រាមដៃ ដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ។

ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន បណ្ណាធិការ ឬអ្នកតំណាង ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
    - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/និង
    - លិខិតទទួលចុះបញ្ជីនូវការបង្កើតសាខា ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ (សម្រាប់ការចុះបញ្ជីសាខា) ឬ/និង
    - លក្ខន្តិកៈក្រុមហ៊ុនសម្រាប់នីតិបុគ្គល ឬ/និង
    - ព័ត៌មានគណនីធនាគាររបស់សហគ្រាស ដូចជាលិខិតបញ្ជាក់ គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ។
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធករ ឬម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង និងអ្នកគ្រប់គ្រងសាខា**
    - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
    - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។
- **ឯកសារបញ្ជាក់ទីតាំងទីចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង**
    - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
    - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ
- **ឯកសារផ្សេងៗ**
    - វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់)
    - អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)។

**គ. សមាគម និងអង្គការនានា**

ប្រធានសមាគម ប្រធានអង្គការនានាដែលធ្វើអាជីវកម្ម ឬអ្នកតំណាងណាមួយដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កែនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ និងតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**

- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ឬ/និង
- លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ឬ/និង
- ព័ត៌មានគណនីធនាគារ ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ (សម្រាប់តែសមាគម ឬអង្គការនានា ដែលធ្វើអាជីវកម្ម)

• **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធាន ឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាង សមាគម ឬអង្គការនានា។

• **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**២- អ្នកជាប់ពន្ធដទៃទៀត**

អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល០៣ខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០ លានរៀល ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ និងភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬច្បាប់ថតចម្លងនៃឯកសារទាំងឡាយដែលមានបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម ÷

• **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយ ក្រសួង ស្ថាប័នពាក់ព័ន្ធ (បើមាន)

• **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់កម្មសិទ្ធិករ**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះ និងចុះហត្ថលេខាទទួលខុសត្រូវដោយម្ចាស់រូបថត។

• **ឯកសារបញ្ជាក់ទីតាំងអាជីវកម្មដ្ឋាន**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**៣- ការប្រើប្រាស់អាសយដ្ឋានក្នុងការចុះបញ្ជីពន្ធដារ និងតម្រូវការឯកសារភ្ជាប់បន្ថែម**

សម្រាប់គោលដៅនៃការចុះបញ្ជីពន្ធដារ អាសយដ្ឋាននៃទីតាំងរបស់ស្ថាប័ន ឬទីចាត់ការសហគ្រាស ឬសាខាសហគ្រាស ឬសមាគម ឬអង្គការនានា ដែលគ្មានអគារ (ដីទំនេរ) ឬមានសំណង់ទើបតែចាប់ផ្តើមសាងសង់

មិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាអាសយដ្ឋានសម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធដែលមានអាសយដ្ឋានស្នាក់នៅ ខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន អ្នកជាប់ពន្ធត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៨.- ការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី**

១. អនុលោមតាមមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធបានចុះបញ្ជីពន្ធដាររួចហើយ ត្រូវបានតម្រូវឱ្យធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ក្នុងករណីដែលព័ត៌មានណាមួយក្នុងចំណោមព័ត៌មានខាងក្រោមនេះត្រូវបានផ្លាស់ប្តូរ÷

ក. នាមករណ៍សហគ្រាស

ខ. អាសយដ្ឋានទីចាត់ការ កន្លែងប្រកបអាជីវកម្មជាគោលដើម ឬសាខា ឃ្លាំងរបស់សគ្រាស

គ. អាសយដ្ឋានម្ចាស់សហគ្រាស អភិបាល ឬបណ្ណាធិការ របស់សហគ្រាស

ឃ. ទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស

ង. កម្មវត្ថុអាជីវកម្ម

ច. ការផ្ទេរ ការបញ្ឈប់អាជីវកម្ម

ឆ. សមាសភាពអ្នកគ្រប់គ្រង

ជ. អ្នកទទួលបន្ទុកកិច្ចការពន្ធ

ឈ. លេខគណនីធនាគារសហគ្រាស

ញ. លេខទំនាក់ទំនង (លេខទូរស័ព្ទ សារអេឡិកត្រូនិក)។

២. អ្នកជាប់ពន្ធត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្តូរព័ត៌មានដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ដើម្បីធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងប្រការ៧ នៃប្រកាសនេះ។

៣. ចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរអាសយដ្ឋានទីចាត់ការសហគ្រាស ឬទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស ដែលនាំឱ្យមានការផ្លាស់ប្តូរពីការគ្រប់គ្រងរបស់អង្គភាពពន្ធដារមួយ ទៅអង្គភាពពន្ធដារមួយទៀត ត្រូវធ្វើការស្នើសុំផ្លាស់ប្តូរអង្គភាពទៅតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសាពើពន្ធ។

៤. ចំពោះអ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ប្រធានស្ថាប័នរដ្ឋ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ប្រធានអង្គការមិនមែនរដ្ឋាភិបាល ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ៩.- កម្រៃសេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. កម្រៃសេវាចុះបញ្ជីពន្ធដារមានដូចខាងក្រោម÷

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ដែលបានស្នើសុំ ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌ១ នៃប្រការ៧ នៃប្រកាសនេះ
- ២០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ ខែ ណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល ដែលបានស្នើសុំដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៧ នៃប្រកាសនេះ
- ៤០០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា ដែលបានស្នើសុំ ដូចមានចែងក្នុងវាក្យខណ្ឌ ខ និង វាក្យខណ្ឌ គ នៃកថាខណ្ឌ១ នៃប្រការ៧ នៃប្រកាសនេះ។

២. កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះមានដូចខាងក្រោម÷

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ
- ១០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល០៣ខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០ លានរៀល
- ២០០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា។

៣. កម្រៃសេវាដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៩ នៃប្រការនេះ ត្រូវអនុវត្តផងដែរចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មាននៅលើប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬស្នើសុំបោះពុម្ពឡើងវិញនូវ ប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។ ដោយឡែកការស្នើសុំបោះពុម្ពប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារឡើងវិញ អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យបង់កម្រៃសេវា ចំនួន ៥ ០០០ រៀល។

**ប្រការ ១០.-ការបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធ ត្រូវចេញលិខិតបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ដោយបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារបន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ១១.- រយៈពេលទទួលបានការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. អ្នកជាប់ពន្ធអាចទទួលបានសេចក្តីសម្រេចចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសក្នុងរយៈពេល÷

- ០១ថ្ងៃ ទៅ ០៧ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិក (E-registration)

- ០៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

២. ក្រោយពេលចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសរួចរាល់ រដ្ឋបាលសារពើពន្ធត្រូវចុះដល់ទីតាំងផ្ទាល់របស់សហគ្រាស ដើម្បីថតរូបទីតាំង និងកត់ត្រាទិន្នន័យរបស់ទីតាំងសហគ្រាស (GPS) ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រគល់ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ ដោយមានការចុះហត្ថលេខាទទួលត្រឹមត្រូវពីអ្នកជាប់ពន្ធ។

៣. ឯកសារផ្លូវការ នៃការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលត្រូវប្រគល់ទទួលមានដូចខាងក្រោម÷

**ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម អង្គការនានា ដែលមិនប្រកបអាជីវកម្ម**

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

**ខ. សហគ្រាសឯកបុគ្គល សហគ្រាសនីតិបុគ្គល សមាគម និងអង្គការនានា ដែលប្រកបអាជីវកម្ម**

- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណពន្ធប៉ាតង់ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

**គ. អ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០លានរៀល ឬមានផលរបរក្នុងរយៈពេលបីខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល**

- លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ

**ប្រការ ១២.-សិទ្ធិរបស់រដ្ឋបាលសារពើពន្ធ**

អនុលោមតាមមាត្រា១០៣ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីជាឯកតោភាគីចំពោះ អ្នកជាប់ពន្ធដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានមកចុះបញ្ជី។ ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី និងកំណត់នូវអ្នកតំណាងណាមួយរបស់សហគ្រាស ដើម្បីមកថតរូបនិងស្កេនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ក្នុងករណីដែលប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន ប្រធានអង្គការនានា និងអ្នកតំណាង មានការទាក់ទិននឹងការគ្រប់គ្រងសហគ្រាស ឬសមាគម ឬអង្គការនានា ដទៃទៀតដែលមានជំពាក់បំណុលពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការចុះបញ្ជីពន្ធដារ។

**ប្រការ ១៣.-សិទ្ធិរបស់អ្នកជាប់ពន្ធ**

អ្នកជាប់ពន្ធមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំឱ្យពិនិត្យ

ឡើងវិញ លើការបដិសេធការចុះបញ្ជី។ ក្នុងករណីអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចប្តឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ។

**ប្រការ ១៤.- ទោសទណ្ឌ**

ការមិនបានចុះបញ្ជីពន្ធដារ មិនបានធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរដូចមានចែងក្នុងប្រការ៥ និងប្រការ៨ នៃប្រកាសនេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រូវរងទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ១៥.-និរាករណ៍**

ប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៦.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកជាប់ពន្ធដែលមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ៥០៥..........សហវ.ឃក

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតរង្វាន់ឧបត្ថម្ភ របស់មូលនិធិជនពិការ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកមូលនិធិជនពិការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥ /០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ
- បានឃើញអនុក្រឹតលេខ២៩១ អនក្រ.តត ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមូលនិធិជនពិការ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ២១១សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការមួយចំនួន ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**សម្រេច**

**ប្រការ១.** ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០ "ការទិញ" ជំពូក៦១ "សេវាកម្ម" ជំពូក៦២ "អត្ថប្រយោជន៍សង្គម" ជំពូក៦៤"បន្ទុកបុគ្គលិក" នៅមូលនិធិជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការមួយចំនួន ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២.** ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(មូលនិធិជនពិការ) ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**នាយកមូលនិធិជនពិការ**

**ជួរ រតនៈ**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិជនពិការ

## តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី
## របស់មូលនិធិជនពិការ ឆ្នាំ២០១៦

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ជំហានរជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដង | ៦=៣/២ |
| | | | **សរុបរួម** | 6,464,226,000 | 996,449,700 | 824,502,300 | 160,352,900 | 206,125,575 | |
| 60 | | | **សរុបការទិញ** | 4,048,321,800 | 10,726,800 | 10,726,800 | - | 2,681,700 | |
| | 6001 | | **សម្ភារផ្គត់ផ្គង់ថែទាំ** | 419,418,000 | | - | | - | 0% |
| | | 60011 | សម្ភារផ្គត់ផ្គង់ សំអាត និងអនាម័យ | 257,910,000 | | | | - | 0% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 161,508,000 | | | | - | 0% |
| | 6002 | | **សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល** | 383,100,000 | | - | | - | 0% |
| | | 60021 | សម្ភារការិយាល័យ និងការបោះពុម្ព | 383,100,000 | | | | - | 0% |
| | | 60022 | សៀវភៅមើល និងឯកសារ | | | | - | - | 0% |
| | 6004 | | **សំលៀកបំពាក់ និងការតុបតែង** | 182,504,000 | | - | | - | 0% |
| | | 60041 | ឯកសណ្ឋាន | 127,994,000 | | | | - | 0% |
| | | 60042 | សំលៀកបំពាក់ការពារសុវត្ថិភាព | 54,510,000 | | | | - | 0% |
| | 6005 | | **សម្ភារតូចតាច សច្ចារឹម និងសម្ភារៈបរិក្ខារ** | 99,826,800 | 10,726,800 | 10,726,800 | - | 2,681,700 | 100% |
| | | 60051 | សម្ភារ និងបរិក្ខារបច្ចេកទេស | 89,100,000 | | | | - | 0% |
| | | 60053 | សម្ភារប្រើប្រាស់ | 10,726,800 | 10,726,800 | 10,726,800 | - | 2,681,700 | 100% |
| | 6006 | | **ថាមពល និងទឹក** | 217,223,000 | | - | | - | 0% |
| | | 60061 | អគ្គីសនី | 195,299,700 | | | | - | 0% |
| | | 60062 | ទឹក | 21,923,300 | | | | - | 0% |
| | 6007 | | **សម្ភារ បរិក្ខារថែទាំសុខភាព** | 2,746,250,000 | | - | | - | 0% |
| | | 60072 | សម្ភារបរិក្ខារពេទ្យ(ឧបករណ៍ សម្ភារវេជ្ជ និងបរិក្ខារព្យាបាលដោយចលនា) | 316,900,000 | | | | - | 0% |
| | | 60078 | សម្ភារបរិក្ខារផ្សេងៗ(ឧបករណ៍ សម្ភារ និងវត្ថុធាតុដើមផលិតអវយវៈសិប្បនិម្មិត និងឈេប) | 2,429,350,000 | | | | - | 0% |
| 61 | | | **សេវាកម្ម** | 809,141,700 | 493,212,900 | 406,713,500 | 74,904,900 | 104,300,625 | |
| | 6101 | | **កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស** | 12,700,000 | | | | - | 0% |
| | 6102 | | **ការជួលមធ្យោបាយដឹកជញ្ជូន** | 13,300,000 | 13,300,000 | 13,300,000 | | 3,325,000 | 100% |
| | 6103 | | **ថ្លៃឈ្នួល និងបន្ទុក(អសច្ចារឹម)** | | | | - | - | 0% |
| | 6104 | | **សោហ៊ុយមណ្ឌលមណ្ឌលបុគ្គលិកក្នុងប្រទេស** | | | | - | - | 0% |
| | 6105 | | **ការថែទាំ និងជួសជុល** | 216,350,000 | 94,480,000 | 94,480,000 | - | 23,620,000 | 100% |
| | | 61052 | ការថែទាំ ជួសជុលអាគារ និងប្រាសាទ | 93,900,000 | | | | - | 0% |
| | | 61053 | ការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 27,970,000 | | | | | 0% |
| | | 61054 | ការថែទាំ បណ្តាញផ្សេងៗ | 11,480,000 | 11,480,000 | 11,480,000 | - | 2,870,000 | 100% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 29,000,000 | 29,000,000 | 29,000,000 | - | 7,250,000 | 100% |
| | | 61057 | ការថែទាំ និងជួសជុលសម្ភារៈឧបករណ៍ការិយាល័យ | 25,000,000 | 25,000,000 | 25,000,000 | - | 6,250,000 | 100% |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានផ្ទេរបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ដំបូងផ្ទេរបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | 61058 | ការថែទាំ និងជួសជុលសម្ភារៈឧបករណ៍បច្ចេកទេស | 29,000,000 | 29,000,000 | 29,000,000 | | 7,250,000 | 100% |
| | 6106 | | **សោហ៊ុយឆានារ៉ាប់រង** | | | | - | - | |
| | 6107 | | **សោហ៊ុយសិក្សាពិសោធន៍នៃការប្រើប្រាស់សេវា** | | | | - | - | |
| | 6110 | | **ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ** | 270,892,700 | 129,856,000 | 92,056,000 | 37,800,000 | 23,014,000 | 71% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 26,536,000 | 26,536,000 | 26,536,000 | - | 6,634,000 | 100% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវអន្តរជាតិ | 5,520,000 | 5,520,000 | 5,520,000 | - | 1,380,000 | 100% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 97,800,000 | 97,800,000 | 60,000,000 | 37,800,000 | 15,000,000 | 61% |
| | | 61104 | សោហ៊ុយពីធីបុណ្យ | 29,500,000 | - | - | - | - | |
| | | 61107 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 111,536,700 | - | - | - | - | |
| | 6111 | | **ចំណាយលើការជាវសារព័ត៌មាន និងឯកសារ** | 2,556,000 | 2,556,000 | 2,556,000 | - | 639,000 | 100% |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 2,556,000 | 2,556,000 | 2,556,000 | - | 639,000 | 100% |
| | 6112 | | **ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស** | 237,104,900 | 237,104,900 | 200,000,000 | 37,104,900 | 50,000,000 | 84% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 41,970,400 | 41,970,400 | 30,000,000 | 11,970,400 | 7,500,000 | 71% |
| | | 61122 | សោហ៊ុយហោប៉ៅ | 29,700,100 | 29,700,100 | 20,000,000 | 9,700,100 | 5,000,000 | 67% |
| | | 61123 | សោហ៊ុយស្នាក់នៅ(និងហូបចុក) | 165,434,400 | 165,434,400 | 150,000,000 | 15,434,400 | 37,500,000 | 91% |
| | 6113 | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | 12,700,000 | 12,700,000 | 11,594,500 | 1,105,500 | 2,898,625 | 91% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | | 61132 | សោហ៊ុយហោប៉ៅ | 4,200,000 | 4,200,000 | 3,094,500 | 1,105,500 | 773,625 | 74% |
| | | 61133 | សោហ៊ុយស្នាក់នៅ(និងហូបចុក) | 3,500,000 | 3,500,000 | 3,500,000 | | 875,000 | 100% |
| | 6114 | | **សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍** | 43,538,100 | 3,216,000 | 3,216,000 | - | 804,000 | 100% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 3,216,000 | 3,216,000 | 3,216,000 | - | 804,000 | 100% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 40,322,100 | | | | - | 0% |
| | 6115 | | **សោហ៊ុយធនាគារ** | | | | - | - | 0% |
| 64 | | | **បន្ទុកបុគ្គលិក** | 1,224,252,500 | 110,000,000 | 103,500,000 | 6,500,000 | 25,875,000 | |
| | 6401 | | **លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ** | 110,000,000 | 110,000,000 | 103,500,000 | 6,500,000 | 25,875,000 | 94% |
| | | 64016 | លាភការក្រុមប្រឹក្សាភិបាល | 110,000,000 | 110,000,000 | 103,500,000 | 6,500,000 | 25,875,000 | 94% |
| | 6403 | | **រង្វាន់ និងប្រាក់បំណាច់ផ្សេងៗ** | 651,600,000 | | - | | - | 0% |
| | | 64038 | ប្រាក់បំណាច់ផ្សេងៗ(ប្រាក់កម្រៃលើកទឹកចិត្ត) | 651,600,000 | | | | - | 0% |
| | 6404 | | **លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ** | 454,500,000 | | - | | - | 0% |
| | | 64041 | បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា | 454,500,000 | | | | - | 0% |
| | 6405 | | **ប្រាក់ឧបត្ថម្ភសង្គមសម្រាប់មន្ត្រីរាជការ** | 8,152,500 | | - | | - | 0% |
| | | 64051 | មន្ត្រីមានជម្ងឺ | 1,200,000 | | | | - | 0% |
| | | 64052 | អ្នកសំរាលកូន | 1,200,000 | | | | - | 0% |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារ និងទុព្វលភាព | 5,752,500 | | | | - | 0% |
| 62 | | | **អត្ថប្រយោជន៍សង្គម** | 382,510,000 | 382,510,000 | 303,562,000 | 78,948,000 | 75,890,500 | |
| | 6202 | | **ជំនួយសង្គមដល់ប្រជាពលរដ្ឋ** | 44,000,000 | 44,000,000 | 44,000,000 | - | 11,000,000 | 100% |
| | | 62022 | ឱសថ | 44,000,000 | 44,000,000 | 44000000 | | 11,000,000 | 100% |
| | 6203 | | **ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌** | 338,510,000 | 338,510,000 | 259,562,000 | 78,948,000 | 64,890,500 | 77% |
| | | 62036 | ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិ និង សម្បទាបណ្តុះបណ្តាលអភិវឌ្ឍ | 338,510,000 | 338,510,000 | 259,562,000 | 78,948,000 | 64,890,500 | 77% |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទានទំដោះបំណុលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | - | ការបើកផ្តល់របបគោលនយោបាយជូនជនពិការក្រីក្រដែលមកទទួលសេវាស្តារលទ្ធភាពពលកម្ម (ថ្លៃធ្វើដំណើរ) | 189,500,000 | 189,500,000 | 154,460,000 | 35,040,000 | 38,615,000 | 82% |
| | | - | ការបើកផ្តល់របបគោលនយោបាយជូនជនពិការក្រីក្រដែលមកទទួលសេវាស្តារលទ្ធភាពពលកម្ម (ថ្លៃអាហារ) | 149,010,000 | 149,010,000 | 105,102,000 | 43,908,000 | 26,275,500 | 71% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦
ឋ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

មិញ បានសុវណ្ណអានិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៦
អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម
មូលនិធិជនពិការ

ប៉ា សំម៉ាធីណោ

បានឃើញ និងពិនិត្យត្រឹមត្រូវ
គណនេយ្យករ

ឃិន សុផល

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦
រដ្ឋទេយ្យករបុរេប្រទាន

ស៊ុន តារី

បានឃើញ និងឯកភាព
ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៦
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៦
នាយកមូលនិធិជនពិការ

ជួរ វឌ្ឍនៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៣ .........សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងរដ្ឋលេខាធិការប្រចាំការ និងរដ្ឋលេខាធិការប្រចាំការរង របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅមូលនិធិជនពិការ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **នាយកមូលនិធិជនពិការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ១២១៥ /០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹតលេខ ៨២អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពី បទបញ្ញាទូទៅគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹតលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹតលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹតលេខ១១៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ
- បានឃើញអនុក្រឹតលេខ២៩១ អនក្រ.តត ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមូលនិធិជនពិការ
- បានឃើញប្រកាសលេខ០០៤សហវ.មប្រកចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា របស់រដ្ឋបាលជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ អំពីការកែសម្រួលប្រការមួយចំនួន ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**សម្រេច**

**ប្រការ១:** ត្រូវបានតែងតាំងមន្ត្រីរាជការនៃមូលនិធិជនពិការ ដូចខាងក្រោម÷

-លោកស្រី **អ៊ុន ដាលី** ឋានៈ មន្ត្រីការិយាល័យហិរញ្ញវត្ថុ និងគណនេយ្យ ជារជ្ជទេយ្យករបុរេប្រទាន

-លោក **ញឹម ចន្ទធឿន** ឋានៈ មន្ត្រីការិយាល័យហិរញ្ញវត្ថុ និងគណនេយ្យ ជារជ្ជទេយ្យករបុរេប្រទានរង

**ប្រការ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣:** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(មូលនិធិជនពិការ) ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**នាយកមូលនិធិជនពិការ**

ជួរ រតនៈ

**កន្លែងទទួល÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ៥៤៦១..........សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៤......ខែឧសភា..ឆ្នាំ២០១៦.

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់ថវិកាសម្រាប់ឆ្នាំ២០១៦
## របស់ក្រសួងព័ត៌មាន

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២១៣ / ១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / ន.ស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៥០៨ / ០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២១៥ / ០១៦ ចុះថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ដែលស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម. ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ. ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ. ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោម
- បានឃើញប្រកាសលេខ ១៩៣៧ សហវ. ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ. ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន

**សម្រេច**

**ប្រការ១.—**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" និងជំពូក៦១ "សេវាកម្ម" នៅក្រសួងព័ត៌មាន សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃ ទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២.—**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.—**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋានទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងព័ត៌មាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**ខៀវ កាញារីទ្ធ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

# តារាងឧបសម្ព័ន្ធវដ្តទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៦ របស់ក្រសួងព័ត៌មាន

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន វដ្តទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិល វដ្តទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ = ២ - ៣ | ៥ = ៣ / ៤ ជុំ | ៦ |
| | | | សរុបរួម | 25,311,000,000 | 6,755,000,000 | 959,020,000 | 5,795,980,000 | 239,755,000 | 14% |
| 60 | | | ការទិញ | 13,177,000,000 | 2,239,000,000 | 309,000,000 | 1,930,000,000 | 77,250,000 | 14% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 1,245,000,000 | 515,000,000 | 45,000,000 | 470,000,000 | 11,250,000 | 9% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់ សម្អាត និងអនាម័យ | 5,000,000 | 5,000,000 | 5,000,000 | 0 | 1,250,000 | 100% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអាគារ ប្រាសាទ និងសំណង់ផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | 0 | 2,500,000 | 100% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 500,000,000 | 500,000,000 | 30,000,000 | 470,000,000 | 7,500,000 | 6% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 730,000,000 | | | 0 | 0 | 0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 1,520,000,000 | 1,520,000,000 | 200,000,000 | 1,320,000,000 | 50,000,000 | 13% |
| | | 60021 | សម្ភារៈការិយាល័យ និងការបោះពុម្ព | 1,500,000,000 | 1,500,000,000 | 180,000,000 | 1,320,000,000 | 45,000,000 | 12% |
| | | 60022 | សៀវភៅមើល និងឯកសារ | 20,000,000 | 20,000,000 | 20,000,000 | 0 | 5,000,000 | 100% |
| | 6004 | | សំលៀកបំពាក់ និងការតុបតែង | 14,000,000 | 4,000,000 | 4,000,000 | 0 | 1,000,000 | 100% |
| | | 60041 | ឯកសណ្ឋាន | 4,000,000 | 4,000,000 | 4,000,000 | 0 | 1,000,000 | 100% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានវិជ្ជមានប្រយោជន៍ | ឥណទានទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិលវិជ្ជមានប្រយោជន៍ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ = ២ - ៣ | ៥ = ៣ / ៤ ជុំ | ៦ |
| | | 60042 | សំលៀកបំពាក់ការពារសុវត្ថិភាព | 10,000,000 | | | 0 | 0 | 0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 6,400,000,000 | 200,000,000 | 60,000,000 | 140,000,000 | 15,000,000 | 30% |
| | | 60051 | សម្ភារៈ និងបរិក្ខារបច្ចេកទេស | 5,500,000,000 | | | 0 | 0 | 0% |
| | | 60052 | សង្ហារឹម | 700,000,000 | | | 0 | 0 | 0% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 200,000,000 | 200,000,000 | 60,000,000 | 140,000,000 | 15,000,000 | 30% |
| | 6006 | | ថាមពល និងទឹក | 3,998,000,000 | | | 0 | 0 | 0% |
| | | 60061 | អគ្គិសនី | 3,938,000,000 | | | 0 | 0 | 0% |
| | | 60062 | ទឹក | 60,000,000 | | | 0 | 0 | 0% |
| 61 | | | សេវាកម្ម | 12,134,000,000 | 4,516,000,000 | 650,020,000 | 3,865,980,000 | 162,505,000 | 14% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 100,000,000 | | | 0 | 0 | 0% |
| | 6105 | | ការថែទាំ និងជួសជុល | 3,101,500,000 | 2,860,500,000 | 259,620,000 | 2,600,880,000 | 64,905,000 | 9% |
| | | 61052 | ការថែទាំ ជួសជុលអាគារផ្សេងៗ និងប្រាសាទ | 777,000,000 | 777,000,000 | 77,700,000 | 699,300,000 | 19,425,000 | 10% |
| | | 61053 | ការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 241,000,000 | | | 0 | 0 | 0% |
| | | 61054 | ការថែទាំបណ្ដាញផ្សេងៗ | 490,000,000 | 490,000,000 | 73,500,000 | 416,500,000 | 18,375,000 | 15% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 1,035,000,000 | 1,035,000,000 | 41,400,000 | 993,600,000 | 10,350,000 | 4% |
| | | 61057 | ការថែទាំ និងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 335,400,000 | 335,400,000 | 40,248,000 | 295,152,000 | 10,062,000 | 12% |
| | | 61058 | ការថែទាំ និងជួសជុលផ្សេងៗ | 223,100,000 | 223,100,000 | 26,772,000 | 196,328,000 | 6,693,000 | 12% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ = ២ - ៣ | ៥ = ៣ / ៤ ជុំ | ៦ |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 5,162,000,000 | | | 0 | 0 | 0% |
